សាលាឧទ្ធរណ៍ភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ៨២៧/ ២៨.៨.២០១២
សាលដីកា
លេខៈ ០២ក្រ.IIIស/២៨.០១.២០១៤

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

***************

## នាមប្រជាពលរដ្ឋខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ដោយមានសមាសភាពដូចតទៅ:

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធាន

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

### តំណាងមហាអយ្យការ

លោក [redacted]

### ក្រឡាបញ្ជី

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៨២៧ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ រវាង ៖

ជនជាប់ចោទឈ្មោះ [redacted] សុវ៉ាត់ ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មុខរបរៈកសិករ កើត និង ទីលំនៅមុនចាប់ខ្លួន [redacted] ស្រុកឆែប ខេត្តព្រះវិហារ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន០៣នាក់, ឃុំខ្លួនថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០។

មានមេធាវីការពារលោក [redacted] វិបុល ។

ជាប់ចោទពីបទៈ ជួញដូរគ្រឿងញៀន ប្រព្រឹត្តនៅ ភូមិលើ សង្កាត់ព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា៣៣ថ្មី កថាខណ្ឌ៤ ចំណុចធ នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

### ដំណើររឿងមានដូចតទៅ ៖

កាលពីថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០ កងរាជអាវុធហត្ថខេត្តកណ្តាល បានធ្វើការចាប់ឈ្មោះ [redacted] សុវ៉ាត់ ក្នុងបទល្មើស និងដកហូតបានវត្ថុតាងជាប្រភេទថ្នាំញៀនមេតំហ្វេតាមីន ទម្ងន់ ៣២០ក្រាម ដែលនៅជាប់នឹងខ្លួនរបស់ជនជាប់ចោទ រួចបានកសាងសំណុំរឿង និងបញ្ជូនខ្លួនជនជាប់ចោទរូបនេះមកកាន់អយ្យការអមសាលាដំបូងខេត្តកណ្តាល ដើម្បីចាត់ការតាមច្បាប់នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៤៣ (ប) ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:៚

១- កែប្រែបទចោទប្រកាន់របស់តំណាងអយ្យការលើឈ្មោះ [redacted] សុវ៉ាត់ ពីបទ ជួញដូរគ្រឿងញៀន តាមមាត្រា៣៣ថ្មី កថាខណ្ឌ៤ ចំណុចឆ នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មកបទ រក្សាទុក ដឹកជញ្ជូន ឬ ជួញដូរ ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤០ កថាខណ្ឌ ៦ ចំណុច ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២ ។

២- ផ្តន្ទាទោសឈ្មោះ [redacted] សុវ៉ាត់ (អត្តសញ្ញាណមាននៅក្នុងសំណុំរឿងស្រាប់) កំណត់ចំនួន ១២ (ដប់ពីរ)ឆ្នាំ គិតចាប់ពីថ្ងៃទីចាប់ខ្លួន ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ ពីបទ រក្សាទុក ដឹកជញ្ជូន ឬ ជួញដូរ ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិលើ សង្កាត់ព្រែករញ្ញាញ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០ តាមមាត្រា៤០ កថាខណ្ឌ៦ ចំណុច៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២។

៣- វត្ថុតាងរូមមាន ថ្នាំញៀនប្រភេទមេតំហ្វេតាមីន (ICE) ចំនួនមួយកញ្ចប់ធំទម្ងន់ ៣២០ (បីរយម្ភៃ) ក្រាម ក្រម៉ាពណ៌ក្រហមចំនួនមួយ និងអាវរងាពណ៌គគីរចំនួនមួយ រឹបអូសបំផ្លាញចោល ក្រោយពេលសាលក្រមចូលជាស្ថាពរ។

- សាលក្រមនេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ ភាគីតំណាងអយ្យការ ទុកសិទ្ធិឲ្យប្តឹងតវ៉ានៅក្នុងកំណត់ច្បាប់។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] សុវ៉ាត់ ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៣ (ប) ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា បញ្ជាក់រង្គហេតុរឿងជូនអង្គសវនាការ

ជនជាប់ចោទឈ្មោះ [redacted] សុវ៉ាត់ឆ្លើយថា ខ្លួនពិតជាបានកាន់យកថ្នាំញៀននេះ នៅព្រំប្រទល់ប្រទេសកម្ពុជា-លាវ ពីឈ្មោះ ឡុង ជាជនជាតិលាវ ឲ្យយកទៅភ្នំពេញ។ អ្នកប្រគល់ថ្នាំញៀននេះមកឲ្យខ្លួន គេគ្រាន់តែប្រាប់ថា ជាថ្នាំញៀន តែគេមិនបានប្រាប់ថា ជាប្រភេទថ្នាំអ្វីទេ។ ក្នុងការនាំថ្នាំនេះយកមកភ្នំពេញនេះ ក្លើ(ឡុង) បានឲ្យតម្លៃកាន់ ៥០០$ (ប្រាំរយដុល្លារអាម៉េរិក)។ មនុស្សដែលជាអ្នកចាំទទួលថ្នាំនោះ ខ្លួនមិនស្គាល់ឈ្មោះគេទេ ហើយក៏មិនដឹងថា ស្រី ឬ ប្រុស ផង តែគេថា ចាំទៅដល់ភ្នំពេញ គេនឹងទាក់ទង និងប្រាប់អ្នកទទួល។ សំណូមពរ សុំតុលាការបន្ធូរបន្ថយទោសដល់រូបខ្លួនផង។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

រឿងនេះ តំណាងមហាអយ្យការយល់ឃើញថា ជនជាប់ចោទបានសារភាពរស់ហើយ ហើយគាត់ប្តឹងឧទ្ធរណ៍ដើម្បីសុំឲ្យសាលាឧទ្ធរណ៍បន្ធូរបន្ថយទោស ដូចនេះសុំក្រុមប្រឹក្សាពិនិត្យ និងពិចារណាតាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្នុងរឿងនេះកូនក្តីខ្លួន បានសារភាពហើយ ហើយបទល្មើសនេះ កម្រិតទោសគឺមានចែងនៅក្នុងមាត្រា៤០ កថាខណ្ឌ៤ ចំណុច៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២ បានបញ្ជាក់ថា ផ្តន្ទាទោសពី ១០ឆ្នាំ ទៅ ២០ឆ្នាំ និងពិន័យជាប្រាក់ពី ៤០.០០០.០០០៛ (សែសិបលានរៀល) ទៅ

១០.០០០.០០០៛ (ដប់លានរៀល) ហើយក្នុងករណីនេះ សាលាដំបូងខេត្តកណ្តាលបានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន១២ឆ្នាំ ចំណែកប្រាក់ពិន័យគាត់មិនបានពិចារណាទេ ដោយសារតែគាត់យល់ឃើញថាកូនក្តីខ្លួនជាជនក្រីក្រ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឲ្យកូនក្តីខ្លួនឈ្មោះ [redacted] សុវ៉ាត់ សូមសំណូមពរ ដោយហេតុថា បទល្មើសគ្រឿងញៀនគឺជាបទឧក្រិដ្ឋមិនអាចយកមាត្រា ៩៣, ៩៤ មកជួយក្នុងការបន្ធូបន្ថយទោសប៉ុន្តែសុំឲ្យលោកប្រធាន ក៏ដូចជាលោកចៅក្រមប្រឹក្សា មេត្តាពិចារណា ចំពោះស្ថានទោសដែលទាបបំផុតដែលមានចែងនៅក្នុងមាត្រា៤០ ទោសដែលទាបបំផុត គឺពី ១០ឆ្នាំ ទៅ ២០ឆ្នាំ និងពិចារណាទៅលើកាលៈទេសៈមួយចំនួនទៀត ដែលនាំឲ្យកូនក្តីខ្លួនប្រព្រឹត្តបទល្មើស កាលៈទេសៈមួយដែលគាត់ទាល់ខ្លាំងមែនទែន ដូចនេះសូមមេត្តាពិចារណាបន្ធូរបន្ថយមកត្រឹមកម្រិតអប្បបរមានៃទោស ដែលមានចែងក្នុងមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ,

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ,

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី,

ក្រោយពីបានពិភាក្សា ជែកញែក ល្អិតល្អន់ តាមច្បាប់

## សភាព្រហ្មទណ្ឌ
## យល់ឃើញថា:

១. បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] សុវ៉ាត់ ជាជនជាប់ចោទ ធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. តាមចម្លើយជនជាប់ចោទថា ខ្លួនពិតជាបានកាន់យកថ្នាំញៀននេះ នៅព្រំប្រទល់ប្រទេសកម្ពុជា-លាវ ពីឈ្មោះ ឡុង ជាជនជាតិលាវ ឲ្យយកទៅភ្នំពេញ។ អ្នកប្រគល់ថ្នាំញៀននេះមកឲ្យខ្លួន គេគ្រាន់តែប្រាប់ថា ជាថ្នាំញៀន តែគេមិនបានប្រាប់ថា ជាប្រភេទថ្នាំអ្វីទេ។ ក្នុងការនាំថ្នាំនេះយកមកភ្នំពេញនេះ គ្នើ(ឡុង) បានឲ្យតម្លៃកាន់ ៥០០$ (ប្រាំរយដុល្លាអាមេរិក)។ មនុស្សដែលជាអ្នកចាំទទួលថ្នាំនោះ ខ្លួនមិនស្គាល់ឈ្មោះគេទេ ហើយក៏មិនដឹងថា ស្រី ឬ ប្រុស ផង តែគេថា ចាំទៅដល់ភ្នំពេញ គេនឹងទាក់ទង និងប្រាប់អ្នកទទួល។

៣. មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] សុវ៉ាត់ ពីបទ រក្សាទុក ដឹកជញ្ជូន ឬ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅ ភូមិលើ ឃុំព្រែករញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០ បទល្មើសមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ៦ ចំណុច៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២។

-ជនជាប់ចោទប្រព្រឹត្តតែម្នាក់ឯង ក្រោយពីបានទទួលថ្នាំញៀនពីជនជាតិឡាវនាំយកមកភ្នំពេញ ពុំមានបក្សពួកឡើយ ប្រព្រឹត្តដោយសារភាពក្រីក្រ ហើយក្រោយពីសមត្ថកិច្ចបង្ក្រាបបានមក ជនជាប់ចោទបានឆ្លើយសារភាពគ្រប់ដំណាក់កាលនៃនីតិវិធី ទាំងនៅសមត្ថកិច្ចនគរបាល ទាំងនៅចំពោះមុខព្រះរាជអាជ្ញា ទាំងនៅចៅក្រមសង្កេតអង្កេត រហូតដល់សវនាការ រួមទាំងសវនាការសាលាឧទ្ធរណ៍ផង ពុំធ្វើឲ្យមានភាពស្មុគស្មាញ ឬ

ឡើយ, ដូច្នេះ សាលាឧទ្ធរណ៍ គួរកែប្រែកម្រិតទណ្ឌកម្ម ឲ្យបានសមស្របនឹងរាកប្បកិរិយានៃជនជាប់ចោទ។

៤. សាលក្រមព្រហ្មទណ្ឌលេខ ៤៣ (ប) ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកណ្តាល សម្រេចមានលក្ខណៈត្រឹមត្រូវ គួរតម្កល់ទុកជាបានការ លើកលែងតែកម្រិតទណ្ឌកម្មដែលបានផ្តន្ទាទោសទៅលើជនជាប់ចោទ គួរកែប្រែឲ្យសមស្រប ដូចយល់ឃើញខាងលើ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១. ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ស៊ុវ៉ាត់ ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៣ (ប) ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការ លើកលែងតែ កម្រិតទណ្ឌកម្មលើជនជាប់ចោទ នៅចំណុចទី២ ត្រូវកែប្រែទៅជា ១០(ដប់)ឆ្នាំ វិញ, ក្រៅពីនេះទុកនៅដដែល។

៣. បង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទ

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ប្រកាសជាសាធារណៈ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ស៊ុវ៉ាត់ និងមេធាវីការពារជនជាប់ចោទ, បើកផ្លូវសាទុក្ខ០១ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកានេះ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

.........................................................................................................

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៤

ក្រឡាបញ្ជី

[redacted]